# ក្រុមការពារក្ដីឱ្យអ្នកស្រី អ៊ឹម ចែម នៅ អ.វ.ត.ក
# DEFENCE TEAM FOR MS. IM CHAEM AT THE ECCC

លោក ប៊ិត ស៊ាងលឹម និងលោក Wayne JORDASH, QC

ទីក្រុងភ្នំពេញ/ទីក្រុងឡុងដ៍

ធ្វើនៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៧

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 12-June-2018, 09:13
CMS/CFO: Sann Rada

**ជូនចំពោះ : អង្គបុរេជំនុំជម្រះ**

**កម្មវត្ថុ : សេចក្តីស្នើលម្អិតសម្រាប់សវនាការផ្ទាល់មាត់នៅក្នុងសំណុំរឿង ០០៤/១**

ជូនចំពោះអង្គចៅក្រមជាទីគោរព

យើងខ្ញុំជាសហមេធាវីការពារក្តីឱ្យអ្នកស្រី អ៊ឹម ចែម តទៅនេះសូមធ្វើការឆ្លើយតបទៅនឹងសេចក្តីជូនដំណឹងរបស់អង្គបុរេជំនុំជម្រះទៅកាន់ភាគីនានាតាមរយៈសារអេឡិចត្រូនិក កាលពីថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៧ ។

យើងខ្ញុំសូមបញ្ជាក់ថា ទាំងសហមេធាវីជាតិ និងសហមេធាវីអន្តរជាតិរបស់អ្នកស្រី អ៊ឹម ចែម អាចចូលរួមក្នុងសវនាការនៅថ្ងៃទី ១១ និង / ឬនៅថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៧ ។

ទាក់ទងនឹងកាលបរិច្ឆេទដែលបានគ្រោងឡើងដោយអង្គបុរេជំនុំជម្រះ យើងខ្ញុំសូមស្នើអង្គបុរេជំនុំជម្រះមេត្តាផ្តល់ពេលវេលាចំនួនពីរម៉ោងទៀត បន្ថែមទៅលើម៉ោងដែលបានផ្តល់ឱ្យពីដំបូង (សរុបគឺមានចំនួនបួនម៉ោង) សម្រាប់ការដាក់សារណាផ្ទាល់មាត់ ។ ការបែងចែកពេលវេលាបែបនេះ គឺសមហេតុផលដើម្បីឱ្យយើងខ្ញុំអាចធ្វើការពិគ្រោះវែកញែកបានគ្រប់ជ្រុងជ្រោយ អំពីវិសាលភាពនៃបញ្ហាមួយចំនួនដែលបានលើកឡើងក្នុងសារណាលាយលក្ខណ៍អក្សរ ។

ជាពិសេស យើងខ្ញុំចាំបាច់ត្រូវធ្វើការបង្ហាញនូវទឡ្ហីករណ៍ផ្ទាល់មាត់ ដើម្បីឆ្លើយតបទៅនឹងសារណាជាលាយលក្ខណ៍អក្សរទាំងអស់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលបានធ្វើឡើងនៅក្នុងដំណើរការនីតិវិធីឧទ្ធរណ៍ពាក់ព័ន្ធនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ។ នៅក្នុងសារណាទាំងនេះ មានបញ្ហាផ្លូវច្បាប់

សំខាន់ៗ និងពោរពេញទៅដោយភាពស្មុគស្មាញជាច្រើន ដែលជាកម្មវត្ថុនៃទឡ្ហីករណ៍ផ្ទាល់មាត់របស់យើងខ្ញុំ ។ ទាំងនេះ គឺរាប់បញ្ចូលទាំងបទដ្ឋានត្រឹមត្រូវនៃការពិនិត្យបណ្តឹងឧទ្ធរណ៍ឡើងវិញ ភាពអាចទទួលយកបាននូវអំណះអំណាងពិតប្រាកដ វិសាលភាពនៃការចោទប្រកាន់ដែលអនុញ្ញាតឱ្យធ្វើទៅបាន និងវិធីសាស្ត្រត្រឹមត្រូវក្នុងការចុះផ្សាយនូវព័ត៌មានដែលមាននៅក្នុងឯកសារដូច្នេះ ។ នេះមិនសំដៅទៅលើទិដ្ឋភាពសំខាន់ៗនៃបណ្តឹងឧទ្ធរណ៍ ព្រមទាំងការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិនៅឡើយទេ ដែលទាំងពីរនេះវាពាក់ព័ន្ធទៅនឹងសំណួរលម្អិតនៃបញ្ហាអង្គហេតុ ដោយសារមិនទាន់ត្រូវបានដោះស្រាយនូវចំណុចមួយចំនួននៃច្បាប់របស់ អ.វ.ត.ក និងច្បាប់អន្តរជាតិ ។

ដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទទួលបានការបែងចែកពេលវេលាឱ្យធ្វើបទបង្ហាញទឡ្ហីករណ៍ផ្ទាល់មាត់នៅចំពោះមុខអង្គបុរេជំនុំជម្រះ វាជាការសមទំនងដែលសារណារបស់ពួកគេ គប្បីទាក់ទងទៅនឹងប្រធានបទនៃការចូលរួមរបស់ពួកគេនៅក្នុងកិច្ចដំណើរការនីតិវិធី ពោលគឺបញ្ហាយុត្តាធិការនៃតុលាការធម្មតារបស់កម្ពុជាលើឧក្រិដ្ឋកម្មទាំងឡាយនាសម័យខ្មែរក្រហម ។ ទន្ទឹមគ្នានេះ សារណារបស់យើងខ្ញុំក៏នឹងត្រូវគ្របដណ្តប់លើប្រធានបទនេះផងដែរ ។

ដើម្បីរៀបចំកិច្ចការក្នុងសំណុំរឿងក្តីរបស់យើងខ្ញុំឱ្យបានពេញលេញ និងក៏ដើម្បីផ្តល់ជំនួយច្រើនបំផុតតាមដែលអាចធ្វើទៅបាន ជូនដល់អង្គបុរេជំនុំជម្រះនៅពេលធ្វើការសម្រេចលើបញ្ហាទាំងអស់ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ យើងខ្ញុំជឿជាក់ថាពេលវេលាបន្ថែមដែលបានស្នើសុំ គឺមានទាំងភាពចាំបាច់ និងសមហេតុផលនៅក្នុងកាលៈទេសៈបច្ចុប្បន្ន ។ យើងខ្ញុំសូមស្នើអង្គបុរេជំនុំជម្រះដោយគោរព មេត្តាផ្តល់នូវពេលវេលាតាមការស្នើចំនួនពីរម៉ោងបន្ថែមទៀត នៅពេលចេញដីកាកំណត់ពេលវេលាសម្រាប់ធ្វើសវនាការផ្ទាល់មាត់នេះ ។

ដោយសេចក្តីគោរពរាប់អានអំពីយើងខ្ញុំ៕

**សហមេធាវីការពារក្តីឱ្យអ្នកស្រី អ៊ឹម ចែម**

BIT Seanglim

Wayne JORDASH, QC